ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តត្បូងឃ្មុំ

លេខ...០៤៦...សជណ.ខតឃ                    ត្បូងឃ្មុំ ថ្ងៃទី...០៥.....ខែ...កញ្ញា...ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
# ស្តីពី
# ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧

រដ្ឋបាលខេត្តត្បូងឃ្មុំ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃ គ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**អ្នកទទួលការត្រូវបានបែកចែកជា៣ប្រភេទ៖**

- ប្រភេទទី១: អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អាគារ និងការងារបេតុង...។ល។)
- **ប្រភេទទី២**: អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដី ស ផ្លូវក្រួសក្រហម...។ល។)
- **ប្រភេទទី៣**:អ្នកទទួលការឯកទេស (អ្នកទទួលការមានឧបករណ៍ និងជំនាញបច្ចេកទេស សម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយ នៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ និងត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងទៅនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិចពីរគម្រោង ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើ លក្ខណៈវិនិច្ឆ័យ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេល និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការ ជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យសម្រេច ។

ករណីបើអ្នកទទួលការមានបំណងចង់ចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ សូមមកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគ នៃសាលាខេត្តត្បូងឃ្មុំ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង៥.០០នាទី ល្ងាច ។ ចំពោះអ្នកទទួលការ ដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យសុំ ចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគ ដោយឥតបង់ថ្លៃ តាមអាស័យដ្ឋានក្នុងបរិវេណសាលាខេត្តត្បូងឃ្មុំ រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមអ្នកទទួលការទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងរួសរាន់មកដាក់ពាក្យ តាមកាលកំណត់ខាងលើកុំបីខាន។

**អភិបាលខេត្ត**

ប្រាជ្ញ ចន្ទ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តត្បូងឃ្មុំ**

លេខ ០៤០ សសរ

ត្បូងឃ្មុំ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១៦

## សេចក្តីសម្រេច
## ស្តីពី
### បង្កើតអនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ
### ដើម្បីរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧

## អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤/៦២៩ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ។
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៨ ស្តីពីការបង្កើត គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ហៅកាត់ថា គ.ជ.អ.ប។
- សេចក្តីណែនាំលេខ ៧៧៩ សជណ/គ.ជ.អ.ប ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧ របស់លេខាធិការដ្ឋាន គ.ជ.អ.ប។

## សម្រេច

**<u>ប្រការ១:</u>** បង្កើតអនុគណៈកម្មការបុរេលក្ខណៈសម្បត្តិអ្នកទទួលការឆ្នាំ២០១៧ ខេត្តត្បូងឃ្មុំ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.លោក ពាង ណារិទ្ធ | នាយករដ្ឋបាលសាលាខេត្តត្បូងឃ្មុំ | ជាប្រធាន |
| ២.លោក វ៉ា គឹមហេង | នាយកទីចាត់ការផែនការ និងវិនិយោគ ខេត្តត្បូងឃ្មុំ | ជាអនុប្រធាន |
| ៣.លោក មិត្ត ផល្លី | នាយករងទីចាត់ការផែនការ និងវិនិយោគ ខេត្តត្បូងឃ្មុំ | ជាសមាជិក |
| ៤.លោក គុន ស៊ុនលី | ប្រធានការិយាល័យគាំទ្រមូលដ្ឋាន នៃទីចាត់ការផែនការ និងវិនិយោគខេត្តត្បូងឃ្មុំ | ជាសមាជិក |
| ៥.លោក នុត ផារិន | ប្រធានការិយាល័យផែនការ នៃទីចាត់ការផែនការ និងវិនិយោគខេត្តត្បូងឃ្មុំ | ជាសមាជិក |
| ៦.លោក ផន សុខជា | ប្រធានការិយាល័យវិនិយោគ នៃទីចាត់ការផែនការ និងវិនិយោគខេត្តត្បូងឃ្មុំ | ជាសមាជិក |
| ៧.លោក កាន់ គុនលី | ប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តត្បូងឃ្មុំ | ជាសមាជិក |
| ៨.លោក អ៊ី ឡៃថេង | ចៅសង្កាត់វិហារលួង ក្រុងសួង ខេត្តត្បូងឃ្មុំ | ជាសមាជិក |
| ៩.លោក ទ្រី ប៊ុនអ៊ី | ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិ(ផ.អ.៣) | ជាអ្នកសង្កេតការ |
| ១០.លោក ម៉ង់ ហុងគ្រី | ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ(ផ.អ.៣) | ជាអ្នកសង្កេតការ |

**ប្រការ២:** អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ វាយតម្លៃអ្នកទទួលការឆ្នាំ២០១៧ មានភារកិច្ចនិងការទទួលខុសត្រូវដូចខាងក្រោម៖

- រៀបចំប្រកាសជូនដំណឹង ស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ជាសាធារណៈ និងតម្លាភាព ផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈក្តារព័ត៌មានខាងមុខទីចាត់ការផែនការ និងវិនិយោគខេត្ត សាលាក្រុង សាលាស្រុក វិទ្យុ ទូរទស្សន៍ ក្នុងខេត្ត និងគេហទំព័រលេខាធិការដ្ឋាន គ.ជ.អ.ប។
- រៀបចំប្រជុំផ្សព្វផ្សាយស្តីពីនីតិវិធី និងដំណើរការរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ឆ្នាំ២០១៧។
- កំណត់កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យសុំចុះឈ្មោះអ្នកទទួលការ ប្រកបដោយតម្លាភាព។
- ពិនិត្យសំណុំឯកសារដាក់ពាក្យរបស់អ្នកទទួលការ និងរៀបចំចាត់តាំងក្រុមការងារ ដើម្បីចុះវាយតម្លៃស្នាដៃបទពិសោធន៍ បុគ្គលិកបច្ចេកទេស សម្ភារៈ គ្រឿងចក្រអ្នកទទួលការដល់ទីកន្លែង។
- សហការជាមួយទីចាត់ការផែនការ និងវិនិយោគ ដើម្បីជួយជំរុញឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការវាយតម្លៃការងាររបស់អ្នកទទួលការឆ្នាំ២០១៥ និងឆ្នាំ២០១៦ ព្រមទាំងបូកសរុបរាយការណ៍។
- រៀបចំរបាយការណ៍វាយតម្លៃ របស់អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ បញ្ជីឈ្មោះអ្នកទទួលការ ដែលមិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងរៀបចំកំណត់ហេតុ របាយការណ៍ ឯកសារពាក់ព័ន្ធនានា ដើម្បីដាក់ជូនឯកឧត្តមអភិបាលខេត្តពិនិត្យ និងសម្រេច។

**ប្រការ៣:** លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤:** នាយករដ្ឋបាលសាលាខេត្ត ទីចាត់ការទាំង៥ចំណុះសាលាខេត្ត និងអង្គភាពលទ្ធកម្មខេត្ត អភិបាលក្រុង ស្រុក មេឃុំ ចៅសង្កាត់ក្នុងខេត្ត មន្ទីរ-អង្គភាព ពាក់ព័ន្ធ និង អស់លោក ដែលមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឲ្យទទួលបានលទ្ធផលល្អប្រសើរ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**អភិបាលខេត្ត**

**ប្រាជ្ញ ចន្ទ**

**កន្លែងទទួល**

- ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ក្រុមប្រឹក្សាខេត្ត
(ដើម្បីជូនជ្រាប)
- ដូចប្រការ៤
(ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ